**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៥៣ សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីជួយសម្របសម្រួលការងាររៀបចំដាក់បញ្ចូល ទីតាំងអតីតមន្ទីរឃុំឃាំង១៣ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និង មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីជួយសម្របសម្រួលការងាររៀបចំដាក់បញ្ចូលទីតាំងអតីតមន្ទីរឃុំឃាំង១៣ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ប្រធាន |
| ២- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |

| | |
|---|---|
| ៣- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៥- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦- តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៧- តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ៨- តំណាងក្រសួងបរិស្ថាន | សមាជិក |
| ៩- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១០- តំណាងក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១១- តំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១២- តំណាងរដ្ឋបាលរាជធានីភ្នំពេញ | សមាជិក |
| ១៣- តំណាងរដ្ឋបាលខេត្តកំពង់ឆ្នាំង | សមាជិក |
| ១៤- តំណាងរដ្ឋបាលខេត្តកំពង់ស្ពឺ | សមាជិក។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មការអន្តរក្រសួងនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានគណៈកម្មការអន្តរក្រសួងនេះ។

**ប្រការ២.-**

គណៈកម្មការនេះមានភារកិច្ចដូចតទៅៈ

- ពិនិត្យ សិក្សាស្រាវជ្រាវ វាយតម្លៃ និងរៀបចំកំណត់តំបន់អតីតមន្ទីរឃុំឃាំង១៣ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក
- កំណត់ព្រំ និងដោះស្រាយផលប៉ះពាល់នានា ពាក់ព័ន្ធនឹងបរិស្ថាន ព្រៃឈើ និងប្រជាជនក្នុងតំបន់
- រៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ដើម្បីកំណត់តំបន់អតីតមន្ទីរឃុំឃាំង១៣ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក
- បោះបង្គោលការពារតំបន់អតីតមន្ទីរឃុំឃាំង១៣ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ទៅតាមការកំណត់របស់ព្រះរាជក្រឹត្យ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីរាជរដ្ឋាភិបាល
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូននាយករដ្ឋមន្ត្រី តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៣.-**

អនុប្រធាននិងសមាជិកនៃគណៈកម្មការអន្តរក្រសួង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

គណៈកម្មការអន្តរក្រសួង មានសិទ្ធិបង្កើតក្រុមការងារបច្ចេកទេស ដោយសេចក្តីសម្រេចរបស់ប្រធាន ដើម្បីអនុវត្តការងារតាមការចាំបាច់។

គណៈកម្មការអន្តរក្រសួង មានសិទ្ធិប្រើត្រារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានីខេត្តពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ